អង្គការពលកម្មអន្តរជាតិ



# គោលនយោបាយសង្ខេប របស់អង្គការពលកម្មអន្តរជាតិ ស្ដីពីការងាររបស់យុវជន នៅក្នុងប្រទេសកម្ពុជា

ការិយាល័យអនុតំបន់នៃអង្គការពលកម្មអន្តរជាតិសំរាប់អាស៊ីបូព៌ា

# គោលនយោបាយសង្ខេប
# របស់អង្គការពលកម្មអន្តរជាតិ
# ស្តីពីការងាររបស់យុវជន
# នៅក្នុងប្រទេសកម្ពុជា

២០០៧

ការិយាល័យអនុតំបន់នៃអង្គការពលកម្មអន្តរជាតិសំរាប់អាស៊ីបូព៌ា

**រក្សាសិទ្ធិ © អង្គការពលកម្មអន្តរជាតិ ២០០៧**
**បោះពុម្ពផ្សាយលើកទីមួយនៅឆ្នាំ ២០០៧**

ការបោះពុម្ពផ្សាយនានារបស់ការិយាល័យអង្គការពលកម្មអន្តរជាតិ ទទួលបានការរក្សាសិទ្ធិដោយអនុលោមតាមពិធីសារទី ២ នៃអនុសញ្ញាស្តីពីសិទ្ធិលើកម្មសិទ្ធិបញ្ញាជាសកល ។ តែទោះជាយ៉ាងនេះក្តី ដំណកស្រង់ខ្លីៗពីការបោះពុម្ពផ្សាយទាំងនេះ អាចត្រូវបានអនុញ្ញាតដោយពុំចាំបាច់សុំការអនុញ្ញាតឡើយ ដរាបណាប្រភពនៃការដកស្រង់នេះត្រូវបានបញ្ជាក់។ ចំពោះការផលិតឡើងវិញ ឬ ការបកប្រែ ត្រូវដាក់ពាក្យស្នើសុំទៅកាន់ផ្នែកបោះពុម្ពផ្សាយ (សិទ្ធិ និង ការអនុញ្ញាត) នៃការិយាល័យអង្គការពលកម្មអន្តរជាតិ ដែលមានអាសយដ្ឋាន CH-1211 Geneva 22 ប្រទេសស្វីស ។ ការិយាល័យអង្គការពលកម្មអន្តរជាតិ សូមស្វាគមន៍ចំពោះការដាក់ពាក្យសុំទាំងអស់ ។

បណ្ណាល័យ ស្ថាប័ន និង អ្នកប្រើប្រាស់ផ្សេងៗទៀត ដែលបានចុះបញ្ជីនៅក្នុងចក្រភពអង់គ្លេសជាមួយនឹងទីភ្នាក់ងារផ្តល់សិទ្ធិកម្មសិទ្ធិបញ្ញា (Copyright Licensing Agency) ដែលមានអាសយដ្ឋាន 90 Tottenham Court Road, London W1T 4LP [ទូរសារៈ (+44) (0)20 7631 5500; អ៊ីម៉ែលៈ cla@cla.co.uk] នៅក្នុងសហរដ្ឋអាមេរិកជាមួយនឹងមជ្ឈមណ្ឌលផ្តល់ការអនុញ្ញាតលើកម្មសិទ្ធិបញ្ញា (Copyright Clearance Center) អាសយដ្ឋាន 222 Rosewood Drive, Danvers, MA 01923 [ទូរសារៈ (+1) (978) 750 4470; អ៊ីម៉ែលៈ info@copyright.com] ឬ នៅប្រទេសដទៃទៀតជាមួយនឹងអង្គការនៃសិទ្ធិការផលិតឡើងវិញ (Reproduction Rights Organization) ដែលពាក់ព័ន្ធ អាចធ្វើការថតចំលងបាន ដោយអនុលោមតាមអាជ្ញាប័ណ្ណដែលផ្តល់អោយពួកគេដើម្បីគោលបំណងនេះ ។

ILO Cataloguing in Publication Data

ILO policy brief on youth employment in Cambodia / International Labour Office. - Phnom Penh: ILO, 2007
16 p.

ISBN: 978-92-2-820112-3; 978-92-2-820113-0 (web pdf)

International Labour Office

youth employment / youth unemployment / employment policy / role of ILO / Cambodia

13.01.3

Also available in English: ILO policy brief on youth employment in Cambodia
ISBN 978-92-2-120112-0; 978-92-2-120113-7 (web pdf), Phnom Penh, 2007

ការពិពណ៌នាដែលប្រើប្រាស់នៅក្នុងការបោះពុម្ពនានារបស់អង្គការពលកម្មអន្តរជាតិ ដែលអនុលោមតាមការអនុវត្តន៍របស់អង្គការសហប្រជាជាតិ នឹង ការលើកយកមកបង្ហាញនានាដែលមាននៅក្នុងការបោះពុម្ពផ្សាយទាំងនេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ការិយាល័យអង្គការពលកម្មអន្តរជាតិ ទាក់ទងនឹងស្ថានភាពគតិយុត្តិរបស់ប្រទេសណាមួយ វិស័យ ឬ ព្រំដែននៃសិទ្ធិអំណាចរបស់ប្រទេសនោះ ឬ ទាក់ទងនឹងការកំណត់ព្រំដែនរបស់ប្រទេសណានោះឡើយ ។

ការទទួលខុសត្រូវចំពោះទស្សនៈដែលបានបង្ហាញនៅក្នុងការសិក្សា អត្ថបទដែលមានចុះហត្ថលេខា និង អត្ថបទចែកចាយផ្សេងៗទៀត គឺធ្លាក់ទៅលើអ្នកនិពន្ធទាំងស្រុង ហើយការបោះពុម្ពផ្សាយមិនមែនសំដៅលើការគាំទ្ររបស់ការិយាល័យអង្គការពលកម្មអន្តរជាតិ លើទស្សនៈយោបល់ដែលបញ្ចេញនៅក្នុងការបោះពុម្ពផ្សាយនោះទេ ។

ការយោងលើឈ្មោះក្រុមហ៊ុន ផលិតផលពាណិជ្ជកម្ម និង ដំណើរការផ្សេងៗទៀត មិនមែនបង្ហាញពីការគាំទ្ររបស់ការិយាល័យអង្គការពលកម្មអន្តរជាតិនោះទេ ហើយការខកខានមិនបានលើកឡើងពីក្រុមហ៊ុន ផលិតផលពាណិជ្ជកម្ម ឬ ដំណើរការណាមួយ ក៏មិនមែនជាសញ្ញាបដិសេធមិនគាំទ្រនោះដែរ។

ការបោះពុម្ពផ្សាយរបស់អង្គការពលកម្មអន្តរជាតិ អាចរកបាននៅតាមបណ្ណាគារធំៗ ឬ ការិយាល័យក្នុងស្រុករបស់អង្គការពលកម្មអន្តរជាតិ នៅក្នុងប្រទេសជាច្រើន ឬ ដោយផ្ទាល់ពីផ្នែកបោះពុម្ពផ្សាយរបស់អង្គការពលកម្មអន្តរជាតិ ដែលមានអាសយដ្ឋាន CH-1211 Geneva 22 ប្រទេសស្វីស ។ សៀវភៅរាយឈ្មោះ ឬ បញ្ជីនៃការបោះពុម្ពផ្សាយថ្មីៗ អាចរកបានដោយមិនគិតថ្លៃ តាមរយៈអាសយដ្ឋានខាងលើ ឬ តាមរយៈអ៊ីម៉ែល pubvente@ilo.org ។

សូមចូលមើលវ៉ិបសាយរបស់យើងខ្ញុំតាមរយៈ www.ilo.org/publns ។

**បោះពុម្ពនៅប្រទេសកម្ពុជា**

# ទិដ្ឋភាពសង្ខេបរួម

ប្រទេសកម្ពុជា មានចំនួនប្រជាជនក្មេងដែលមានអាយុក្រោម ១៥ ឆ្នាំ ចំនួន ៣៩% នៃចំនួនប្រជាជនសរុប នៅក្នុងឆ្នាំ ២០០៤ ដែលភាគរយនេះថយចុះពីចំនួន ៤៣% កាលពីឆ្នាំ ១៩៩៨ ។ គិតត្រឹមឆ្នាំ ២០០៤ អត្រាអ្នកនៅក្នុងបន្ទុក ដែលបង្ហាញពីចំនួនកុមារ និង មនុស្សចាស់ គិតជាភាគរយនៃក្រុមមនុស្សវ័យកណ្តាល មានចំនួន ៧៤% [១] ។ យុវជនដែលមានអាយុពី ១៥ ដល់ ២៤ ឆ្នាំ មានចំនួន ២២% នៃចំនួនប្រជាជនសរុបនៅក្នុងឆ្នាំនោះ ។ យុវជនក្នុងចំនួនដ៏ច្រើនកំពុងបោះជំហានចូលទៅក្នុងកំលាំងការងារ ដែលនេះគឺជាលទ្ធផលនៃកំណើនចំនួនកុមារយ៉ាងច្រើនសន្ធឹកសន្ធាប់នៅទសវត្សរ៍ ១៩៨០ ។ វិធានការនានាត្រូវតែយកមកអនុវត្តដើម្បីធានាអោយបានច្បាស់ថា ចំនួនយុវជនមិនបន្ថែមលើចំនួនអ្នកមានការងារធ្វើមិនគ្រប់គ្រាន់នៅតាមតំបន់ជនបទ ឬ ធ្វើអោយមានអត្រាអ្នកគ្មានការងារធ្វើនៅទីក្រុងកាន់តែខ្ពស់ជាងមុននោះឡើយ ប៉ុន្តែផ្ទុយទៅវិញចូលរួមចំណែកជំរុញដល់កំណើន និង ការអភិវឌ្ឍន៍ តាមរយៈការងារប្រកបដោយផលិតភាព ។

### ពីរ៉ាមីតនៃចំនួនប្រជាជន ប្រទេសកម្ពុជា ឆ្នាំ ២០០៤




ប្រភព: វិទ្យាស្ថានជាតិស្ថិតិ: ការស្ទាបស្ទង់អន្តរជំរឿនពីចំនួនប្រជាជនក្នុងប្រទេសកម្ពុជា ឆ្នាំ ២០០៤ របាយការណ៍ទូទៅ ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ ២០០៤ រូបភាពទី ២ ទំព័រទី ១៣ ។

១ វិទ្យាស្ថានជាតិស្ថិតិ: *ការស្ទាបស្ទង់អន្តរជំរឿនពីចំនួនប្រជាជនក្នុងប្រទេសកម្ពុជាឆ្នាំ ២០០៤ របាយការណ៍ទូទៅ* ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០០៤ ទំព័រទី ១៦ ។

ស្ត្រីក្មេងៗជាច្រើននាក់ បាននិងកំពុងស្វែងរកឱកាសការងារនៅក្នុងរោងចក្រកាត់ដេររបស់ប្រទេសកម្ពុជា ។ ខណៈពេលដែលពួកគេទទួលអត្ថប្រយោជន៍ពីការងារបានប្រាក់កំរៃ ការផ្លាស់ប្តូរនានាដែលទាក់ទងទៅនឹង ល័ក្ខខ័ណ្ឌការងារ បទដ្ឋានការងារ និង បញ្ហាសហជីព ទាំងនៅសហគមន៏ជនបទដែលជាអ្នកបញ្ជូន និង នៅទីក្រុងជាកន្លែងគោលដៅដូចជាទីក្រុងភ្នំពេញជាដើម បានជំរុញអោយមានការជជែកវែកញែកយ៉ាងទូលំទូលាយអំពីគោលនយោបាយការងារ ការអភិវឌ្ឍន៏ និង ពាណិជ្ជកម្ម [២] ។ តាមពិតទៅ កម្មករនិយោជិតកាត់ដេរតំណាងអោយភាគរយមួយតូចតែប៉ុណ្ណោះ នៃកំលាំងការងារសរុប ។ ប៉ុន្តែមានការរំពឹងទុកខ្ពស់ទៅលើការផ្ញើប្រាក់ជាទៀងទាត់ទៅតំបន់ជនបទ ដែលនេះគឺជាការចូលរួមចំណែកយ៉ាងសំខាន់មួយ ចំពោះជីវភាពរស់នៅតាមទីជនបទ [៣] ។ ស្ថេរភាពនៃការងារទាំងនេះក៏អាស្រ័យផងដែរលើកិច្ចព្រមព្រៀងអន្តរជាតិ និង ទីផ្សារសកល ។

ចំណែករបស់យុវជន ( ១៥-២៤ ឆ្នាំ) និង មនុស្សពេញវ័យ ( ២៥+ ឆ្នាំ)
នៅក្នុងចំនួនអ្នកគ្មានការងារធ្វើសរុប ភ្នំពេញ ឆ្នាំ ២០០៤




ប្រភពៈ ឯ. សន ស៊ីថនៈ "ចំនួនប្រជាជនដែលសកម្មខាងសេដ្ឋកិច្ច ( ទិន្នន័យ ១២ ខែ ឆ្នាំ ២០០៤) បទបង្ហាញនាងសិក្ខាសាលាស្តីពីការវិភាគស្ថិតិហិរញ្ញវត្ថុរបស់ CSES ២០០៣-០៤" វិទ្យាស្ថានជាតិស្ថិតិ ភ្នំពេញ ១៦-១៧ មិថុនា ២០០៥ ។

ប្រសិនបើអ្នកគ្មានមានការងារធ្វើ ត្រូវបានគេកំណត់និយមន័យអោយថាជាអ្នកដែលធ្វើការងារតិចជាងមួយម៉ោងក្នុងមួយសប្តាហ៏ ហើយមានពេលនិងកំពុងស្វែងរកការងារធ្វើនោះ អត្រាអ្នកគ្មានការងារធ្វើដែលគេវាស់វែងឃើញ [៤] នៅក្នុងប្រទេសកម្ពុជា មានក៏រិតទាបខ្លាំងតិចជាងមួយភាគរយនៅក្នុងឆ្នាំ ២០០៤ ។ ប៉ុន្តែ អត្រាគ្មានការងារធ្វើរបស់យុវជនមាន

២ UNIFEM: *ចំណែកយុត្តិធមិសំរាប់ស្ត្រីៈ ការសិក្សាវាយតំលៃលើយេនឌ័រ ក្នុងប្រទេសកម្ពុជា* ភ្នំពេញ ខែមេសា ឆ្នាំ ២០០៥ ទំព័រទី ៤៧-៤៩ ។

៣ ធនាគារពិភពលោកៈ *ប្រទេសកម្ពុជាៈ កាត់បន្ថយភាពក្រីក្រអោយបាននៅត្រឹមឆ្នាំ ២០១៥? ការសិក្សាវាយតំលៃលើភាពក្រីក្រ ឆ្នាំ ២០០៦* របាយការណ៏លេខ 35213-KH ឯកសាររបស់ធនាគារពិភពលោកតំបន់អាស៊ីខាងកើត និង ប៉ាស៊ីហ្វិក ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ប្រអប់ ៣.២ ទំព័រទី ៤២ ។

៤ អត្រាអ្នកគ្មានការងារធ្វើ គឺជាចំនួនប្រជាជនដែលគ្មានការងារធ្វើគិតជាភាគរយ នៃកំលាំងការងារដែលគេកំណត់ជាចំនួនអ្នកគ្មានការងារធ្វើ និង អ្នកដែលមានការងារធ្វើនៅក្នុងក្រុមដែលមានអាយុដូចគ្នា ។

កំរិតខ្ពស់ជាងមនុស្សពេញវ័យ ។ នៅឆ្នាំ ២០០៤ អត្រាអ្នកគ្មានការងារធ្វើនៅក្នុងទីក្រុងភ្នំពេញមានចំនួន ៦,២% សំរាប់មនុស្សវ័យជំទង់អាយុ ១៥-១៨ ឆ្នាំ និង ៧,៨% សំរាប់មនុស្សទើបពេញវ័យ អាយុ ២០-២៤ ឆ្នាំ ។ យុវជនមានចំនួន ៧២% នៃចំនួនអ្នកគ្មានការងារធ្វើសរុប នៅក្នុងរាជធានីកាលពីឆ្នាំនោះ ។

### អត្រាគ្មានការងារធ្វើរបស់យុវជន និង មនុស្សពេញវ័យ ប្រទេសកម្ពុជា ឆ្នាំ ២០០៤

| | សរុប | ប្រុស | ស្រី | ភ្នំពេញ | ទីក្រុងផ្សេង | ជនបទ |
|---|---|---|---|---|---|---|
| អត្រាគ្មានការងារធ្វើដោយប្រើនិយមន័យ "តឹងរ៉ឹង" | | | | | | |
| ១៥ - ១៩ | ១,៤ | ១,៣ | ១,៤ | ៦,២ | ២,៧ | ០,៩ |
| ២០ - ២៤ | ១,៦ | ១,៩ | ១,២ | ៧,៨ | ១,៤ | ០,៨ |
| ១៥ - ២៤ | ១,៥ | ១,៦ | ១,៣ | ៧,២ | ២,១ | ០,៩ |
| ២៥ + | ០,៦ | ០,៥ | ០,៧ | ១,៤ | ១,០ | ០,៤ |
| ១៥ + | ០,៩ | ០,៩ | ០,៩ | ៣,៣ | ១,៤ | ០,៦ |
| អត្រាគ្មានការងារធ្វើដោយប្រើនិយមន័យ "ធូរស្រាល" | | | | | | |
| ១៥ - ១៩ | ៧,៩ | ៧,៣ | ៨,៥ | ២៤,៨ | ១០,១ | ៦,២ |
| ២០ - ២៤ | ៦,៥ | ៥,៤ | ៧,៦ | ១៦,៦ | ៧,១ | ៥,១ |
| ១៥ - ២៤ | ៧,២ | ៦,៤ | ៨,០ | ២០,១ | ៨,៦ | ៥,៧ |
| ២៥ + | ៤,៧ | ២,៤ | ៦,៩ | ៥,៨ | ៤,៦ | ៤,៦ |
| ១៥ + | ៥,៦ | ៣,៩ | ៧,៣ | ១០,៩ | ៦,០ | ៥,០ |

កំណត់សំគាល់: និយមន័យ "តឹងរ៉ឹង" រួមមានត្រឹមតែអ្នកដែលកំពុងសកម្មស្វែងរកការងារធ្វើតែប៉ុណ្ណោះ ខណៈពេល ដែលនិយមន័យ "ធូរស្រាល" រួមមានអ្នកដែលមិនមានការងារធ្វើហើយមានពេលដើម្បីធ្វើការងារ ប៉ុន្តែមិនចាំបាច់កំពុងស្វែងរកការងារធ្វើឡើយ ។
ប្រភព: វិទ្យាស្ថានជាតិស្ថិតិ: ការសិក្សាលើសង្គមសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៤ ។

ប្រសិនបើនិយមន័យ "ធូរស្រាល" ( ដែលរាប់អ្នកមិនទាន់ធ្វើការ ប៉ុន្តែមានពេលដើម្បីធ្វើការងារ) ត្រូវបានប្រើប្រាស់សំរាប់ភាពគ្មានការងារធ្វើជំនួសអោយនិយមន័យ "តឹងរ៉ឹង" (ដែលរាប់តែអ្នកដែលកំពុងសកម្មស្វែងរកការងារធ្វើ ) វិញនោះ នោះអត្រាអ្នកគ្មានការងារធ្វើនឹងមានកំរិតខ្ពស់ជាងគួរអោយកត់សំគាល់ និង ជាការមួយគួរអោយព្រួយបារម្ភសំរាប់យុវជននៅក្នុងទីក្រុងភ្នំពេញ គឺនៅកំរិត ២០,១% ក្នុងឆ្នាំ ២០០៤ ដែលក្នុងនោះ ២៧,៨% ជាមនុស្សជំទង់ដែលមានអាយុពី ១៥-១៩ ឆ្នាំ និង ១៦,៦% ជាមនុស្សទើបពេញវ័យដែលមានអាយុ ២០-២៤ ឆ្នាំ ។ ការកើនឡើងនូវចំនួនយុវជនដែលត្រូវការការងារធ្វើ និង ជំនាញដែលសមស្រប នឹងនៅបន្តជាបញ្ហាប្រឈមនៅក្នុងឆ្នាំខាងមុខទៀត ។

វាជាការធម្មតាដែលអត្រាយុវជនមានកំរិតខ្ពស់ ពីព្រោះអ្នកដែលទើបចូលប្រឡូកនៅ

ក្នុងកំលាំងការងារ ត្រូវការពេលវេលាដើម្បីស្វែងរកការងារដែលផ្តល់អត្ថប្រយោជន៏ច្រើន ។ វាមានលក្ខណៈពិតប្រាកដជាពិសេសសំរាប់យុវជនមានការអប់រំ ដែលចង់អោយការងារដំបូងរបស់ពួកគេជាការងារដែលសមស្រប ។ ទិដ្ឋភាពមួយទៀតនៃភាពគ្មានការងារធ្វើរបស់អ្នកដែលមានការអប់រំ គឺភាគច្រើននៃយុវជនដែលទទួលបានការអប់រំច្រើនទំនងជាទទួលបានការឧបត្ថម្ភពីគ្រួសារតាមរយៈចំណូលរបស់ក្រុមគ្រួសារ ដែលជួយដល់ពួកគេរហូតទាល់តែពួកគេអាចស្វែងរកមុខតំណែងការងារដែលសាកសម ។ យុវជនដែលមកពីគ្រួសារដែលមានជីវភាពគ្រាន់បើ គឺមិនត្រូវបានភាពក្រីក្រជំរុញអោយទទួលយកឱកាសណាក៏ដោយដែលមកដល់នោះទេ ។

ទោះជាយ៉ាងណាក៏ដោយ ភាពគ្មានការងារធ្វើរបស់យុវជនក្លាយជាក្តីបារម្ភនៅពេលដែលអត្រាគ្មានការងារធ្វើមានកំរិតខ្ពស់ ដោយឆ្លុះបញ្ចាំងថាឱកាសការងារមិនមានកំណើនលឿនគ្រប់គ្រាន់ ដើម្បីសមស្របទៅនឹងកំណើនកំលាំងការងារ ។ អត្រាគ្មានការងារធ្វើខ្ពស់ក៏ឆ្លុះបញ្ចាំងផងដែរពីការពិតដែលថា យុវជនដែលកំពុងស្វែងរកការងារធ្វើដំបូងមិនមានការអប់រំ និង ជំនាញដែលចាំបាច់ ដើម្បីឆ្លើយតបទៅតាមតំរូវការទីផ្សារការងារ ។ ភាពមិនស៊ីគ្នារវាងការអប់រំនិងជំនាញរបស់យុវជន និង តំរូវការចង់បានរបស់និយោជក គឺជាបញ្ហាដែលតែងតែកើតមានឡើងនៅទូទាំងតំបន់ ។ យុវជនក៏ធ្លាក់ទឹកចិត្តផងដែរ នៅពេលដែលធ្វើការងារបានចំណូលទាប និង មានស្ថេរភាពតិចតួច ។ កង្វះខាតការងារសមរម្យ រួមជាមួយនិងភាពគ្មានការងារធ្វើខ្ពស់ អាចធ្វើអោយមានការខ្ជះខ្ជាយសក្តានុពលសំរាប់យុវជន ការបាត់បង់ឱកាសសំរាប់ការអភិវឌ្ឍន៏សេដ្ឋកិច្ច និង ហានិភ័យនៃចលាចលក្នុងសង្គម ។

ការចល័តកន្លែងរស់នៅក្នុងប្រទេស និង ការធ្វើចំណាកស្រុកទៅក្រៅប្រទេសគឺជាបញ្ហាទីផ្សារការងារដ៏សំខាន់មួយ ។ ចំណាកស្រុកនៅក្នុងប្រទេសកម្ពុជា មានការកើនឡើងនៅក្នុងឆ្នាំថ្មីៗនេះ ដោយការចល័តភាគច្រើនធ្វើឡើងពីតំបន់ជនបទមួយទៅជនបទមួយទៀត ។ យ៉ាងណាក៏ដោយ ទីក្រុងភ្នំពេញ និង តំបន់កំពង់ផែនៅជុំវិញក្រុងព្រះសីហនុ គឺជាកន្លែងប្រមូលផ្តុំអ្នកធ្វើចំណាកស្រុកច្រើនជាងគេ ។ អត្រាចំណាកស្រុកថ្មីៗសំរាប់យុវជនមានកំរិតខ្ពស់ ជាពិសេសយុវជនដែលស្ថិតនៅក្នុងវ័យជាង ២០ ឆ្នាំ ។ ជាញឹកញាយ យុវជនបំលាស់ទីទៅជិតនឹងស្ថាប័នផ្តល់ការអប់រំ និង ការបណ្តុះបណ្តាល ។ អ្នកធ្វើចំណាកស្រុកជាច្រើននាក់ព្រមជាមួយនិងគ្រួសាររបស់ពួកគេ ផ្លាស់កន្លែងរស់នៅដោយសារមូលហេតុដែលទាក់ទងនឹងការងារ ។ អ្នកដទៃទៀត បានត្រលប់មកកាន់ផ្ទះរបស់ពួកគេវិញបន្ទាប់ពីព្រាត់ប្រាស់ទីលំនៅដោយសារជំលោះ ឬ គ្រោះមហន្តរាយ ។ ស្រ្តីក្មេងៗមកពីជនបទបានរកការងារធ្វើនៅតាមរោងចក្រកាត់ដេរនៅទីក្រុងភ្នំពេញ ។ ជាងពាក់កណ្តាលនៃស្រ្តីធ្វើចំណាកស្រុកដែលស្ថិតនៅក្នុងកំលាំងការងារនៅតំបន់ទីក្រុង បំរើការងារក្នុងផ្នែកលក់ ឬ ផ្នែកបង្កបង្កើនផល និង នេសាទ។

# បញ្ហាប្រឈមសំខាន់ៗ

## *អ្នកទើបចូលមកថ្មីនៅក្នុងកំលាំងការងារ*

ប្រទេសកម្ពុជាចាំបាច់ត្រូវដោះស្រាយបញ្ហាប្រឈម នៃកំណើនចំនួនយុវជនដែលត្រូវការការងារធ្វើ និង ជំនាញសមស្រប ។ ការប៉ាន់ស្មានឡើងវិញពីចំនួនប្រជាជនដោយប្រើប្រាស់ទិន្នន័យបានមកពីការសិក្សាអន្តរជំរឿនលើប្រជាជនក្នុងប្រទេសកម្ពុជាឆ្នាំ ២០០៤ បង្ហាញពីកំណើនចំនួនយុវជន ដែលមានអាយុ ១៥-២៤ ឆ្នាំ ។ ចំនួនយុវជនសរុបត្រូវបានរំពឹងថានឹងកើនពី ៣,២ លាននាក់ ក្នុងឆ្នាំ ២០០៥ ដល់ ៣,៦ លាននាក់ ក្នុងឆ្នាំ ២០១១ ។ សមាមាត្រនៃចំនួនយុវជនលើចំនួនប្រជាជនសរុប នៅរក្សាត្រឹម ២៤% ។ គេបានប៉ាន់ស្មានថាដល់ឆ្នាំ ២០១១ យុវជនដែលមានអាយុ ១០+ ឆ្នាំ នឹងមានចំនួន ៣០% ហើយអាយុ ១៥+ ឆ្នាំ នឹងមានចំនួន ៣៥% ។ មានការព្រួយបារម្ភថា តើប្រភពនៃកំណើនសំខាន់ៗជាងគេ (ផ្នែកកាត់ដេរ សំណង់ និង ទេសចរណ៍) អាចបន្តស្រូបយកយុវជនស្វែងរកការងារធ្វើប្រមាណ ២៧៥ ០០០ នាក់ ដែលចូលមកកាន់ទីផ្សារការងារជារៀងរាល់ឆ្នាំ ក្នុងកំឡុងពេល ៥ ឆ្នាំទៅមុខទៀតដែរឬទេ ។

## *ការអប់រំ និង ជំនាញ*

ស្ថានភាពមួយដែលបន្សល់ទុកពីអតីតកាល គឺកំរិតទាបនៃធនធានមនុស្ស ។ ការរីកចំរើនផ្នែកអក្ខរកម្ម ការអប់រំ និង ការបណ្តុះបណ្តាល មានសារៈសំខាន់យ៉ាងខ្លាំងដើម្បីសំរេចអោយបាននូវការងារសមរម្យ ។ ខណៈពេលដែលមានភាពជឿនលឿនគួរអោយកត់សំគាល់ខាងផ្នែកអប់រំសំរាប់កុមារី និង ស្ត្រីក្មេងៗ អត្រាចូលរៀនសំរាប់សាលាមធ្យមសិក្សានៅមានកំរិតទាប ដោយមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងរវាងតំបន់ជនបទនិងទីក្រុង ។ ករណីនេះកើតមានឡើងនៅកន្លែងដទៃទៀតផងដែរនៅក្នុងតំបន់ ដោយការទទួលខុសត្រូវសំរាប់ការអប់រំ និង ការបណ្តុះបណ្តាល គឺស្ថិតនៅតាមក្រសួងរបស់រដ្ឋាភិបាលជាច្រើន ដោយមានស្ថាប័នអប់រំ និង បណ្តុះបណ្តាល ជាអ្នកផ្តល់សេវានៅក្នុងវិស័យឯកជន ។

ខណៈពេលដែលកំលាំងការងារជាច្រើនគ្មានជំនាញ ហើយស្វែងរកឱកាសការងារក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ យុវជនដែលមានការអប់រំជាច្រើននាក់មិនអាចស្វែងរកការងារធ្វើបានដោយសារតែភាពមិនស៊ីគ្នារវាងជំនាញ និង បំណងប្រាថ្នា ហើយម្យ៉ាងវិញទៀតដោយសារល័ក្ខខ័ណ្ឌតំរូវអោយមានសំរាប់ការងារ និង មុខតំណែងដែលមាន ។ ដើម្បីកំណត់







ពីតំរូវការជំនាញដែលធ្វើឡើងដោយប្រព័ន្ធអប់រំ និង អ្នកផ្តល់ការបណ្តុះបណ្តាល ចាំបាច់ត្រូវអោយនិយោជកចូលរួមពាក់ព័ន្ធនៅក្នុងការសិក្សាវាយតំលៃពីតំរូវការ និង ការធ្វើផែនការជំនាញ ។

ការអភិវឌ្ឍន៏ធនធានមនុស្ស បានធ្វើដំណើរនៅពីក្រោយតំរូវការទាំងនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន ។ អ្នកដឹកនាំ និង មន្ត្រីបច្ចេកទេសជាន់ខ្ពស់របស់កម្ពុជាបច្ចុប្បន្នកំពុងឈានទៅរកអាយុចូលនិវត្តន៍ ។ មានការភ័យខ្លាចថា ក្រុមមនុស្សជំនាន់ក្រោយមានការអប់រំតិចជាង និង មានការត្រៀមខ្លួនតិចជាង ដើម្បីចាប់យកតួនាទីក្នុងជួរដឹកនាំ និង គ្រប់គ្រង [៥] ។ មិនថានេះគឺជាករណីដែលអាចកើតមាន ឬ ក៏អត់នោះទេ ចាំបាច់ត្រូវធានាថាយុវជនទទួលបានការអប់រំ ការបណ្តុះបណ្តាល និង បទពិសោធន៍ ដើម្បីអាចទទួលយកតួនាទីទាំងនេះនាពេលអនាគត ។

## *អត្រាអ្នកគ្មានការងារធ្វើ*

ខណៈពេលដែលការកំណត់រកអត្រាអ្នកគ្មានការងារធ្វើជារួម ដែលធ្វើឡើងទៅតាមបទដ្ឋានស្ថិតិអន្តរជាតិនៅមានកំរិតទាប អត្រារបស់យុវជនមានកំរិតខ្ពស់ជាងអត្រាសំរាប់មនុស្សពេញវ័យគួរអោយកត់សំគាល់ ។ មនុស្សមួយចំនួនមិនមានការងារធ្វើ ដោយសារតែប្រាក់ឈ្នួលរំពឹងទុក និង បំណងប្រាថ្នាការងារ មិនស្របគ្នាជាមួយនឹងភាពជាក់ស្តែង ។ ការពិតដែលថា យុវជនម្នាក់ក្នុងចំណោមប្រាំអ្នកនៅក្នុងកំលាំងការងារក្នុងរាជធានី ពុំមានការងារធ្វើទោះបីជាមិនមែនគ្រប់គ្នាសុទ្ធតែកំពុងស្វែងរកការងារធ្វើក៏ដោយ គឺគ្រាន់តែជាផ្នែកដ៏សែនតូចមួយនៃការមានការងារធ្វើមិនគ្រប់គ្រាន់តែប៉ុណ្ណោះ ។ អ្នកធ្វើការងារជាច្រើននាក់រួមទាំងយុវជនផងដែរនោះ កំពុងជាប់នៅក្នុងការងារដែលមានផលិតភាពទាប និង មានចំណូលទាប នៅក្នុងការងារក្រៅប្រព័ន្ធ និង តំបន់ជនបទ ។ អ្នកដទៃទៀតត្រូវបានបង្ខំចិត្ត "ដាក់ខ្លួន" ទទួលយកការងារដែលស្ថិតនៅក្រោមកំរិតនៃការអប់រំ និង ការបណ្តុះបណ្តាលរបស់ពួកគេ ។ និស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ប្រឈមនឹងការលំបាកក្នុងការស្វែងរកការងារធ្វើ ។ អ្នកដែលស្វែងរកការងារបានធ្វើជាច្រើន បានត្រឹមតែការងារបណ្តោះអាសន្ន ក្រៅម៉ោង មិនទៀងទាត់ ម្តងម្កាល និង គ្មានស្ថេរភាព នៅក្នុងល័ក្ខខ័ណ្ឌការងារមិនល្អ និង មានភាពឋិតថេរតិចតួចនៃចំណូល [៦] ។ ការមិនមានការងារធ្វើរយៈពេលវែង អាចធ្វើអោយយុវជនប្រឈមមុខនឹងការបាក់ទឹកចិត្ត និង អស់សង្ឃឹម ។

---

៥ Monika Kaing and Sandra D'Amico: *ប្រទេសកម្ពុជា: ការងាររបស់យុវជន និង កិច្ចសន្ទនាសង្គម* ពង្រាងសំណើរដោយ CAMFEBA ខែ មីនា ឆ្នាំ ២០០៧ ទំព័រទី ៧ ។

៦ Elizabeth Morris: *"ការងាររបស់យុវជន - ជំហានបន្ទាប់"* ការផ្សាយរបស់ អង្គការពលកម្មអន្តរជាតិ វ៉ុល ៣ លេខ ៣ ខែ ធ្នូ ឆ្នាំ ២០០៤ ទំព័រ ៦-៧ ។

## ចំណាកស្រុកដើម្បីការងារ

យុវជនទំនងជាផ្លាស់កន្លែងរស់នៅដើម្បីស្វែងរកការងារធ្វើ ច្រើនជាងមនុស្សពេញវ័យ ។ យុវជនជាច្រើននាក់ធ្វើចំណាកស្រុកមកកាន់ទីក្រុងភ្នំពេញ ឬ ស្វែងរកឱកាសថ្មីៗនៅក្រៅប្រទេស ជាពិសេសនៅប្រទេសថៃ និង ម៉ាឡេស៊ី ។ ពួកគេក្នុងចំនួនដ៏ច្រើន គឺជាអ្នកដែលគ្មានជំនាញ និង មិនទាន់បានប្រុងប្រៀបដើម្បីទទួលយកការងារនៅកន្លែងគោលដៅ មិនដឹងពីសិទ្ធិរបស់ពួកគេ ហើយមិនដឹងពីគ្រោះថ្នាក់នានាដូចជា ការជួញដូរ ការកេងប្រវ័ញ្ច និង ការរំលោភបំពានជាដើម ។ យុវជនត្រូវការការរៀបចំអោយបានល្អប្រសើរជាងមុន មុនពេលទទួលយកការងារនៅក្រៅសហគមន៍មូលដ្ឋានរបស់ពួកគេ ។ លើសពីនេះទៅទៀត ទាំងយុវជន ទាំងសហគមន៍ អាចទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់ល្អប្រសើរជាងមុន នូវលុយដែលផ្ញើមក និង ជំនាញដែលទទួលបានតាមរយៈការងារក្រៅស្រុក ។

## យុវជននៅក្នុងសង្គមក្រោយជំលោះ

ជំលោះផ្ទៃក្នុងរយៈពេលយូរ បានបន្សល់នូវផលប៉ះពាល់យ៉ាងធំធេងមកលើសង្គមរបស់ប្រទេសកម្ពុជា ។ អ្នកបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យដែលឈានជើងចូលក្នុងទីផ្សារការងារជាមួយនឹងសញ្ញាប័ត្រ អាចមានការខកចិត្តដោយសារភាពមានកំរិតនៃការងារប្រកបដោយផលិតភាព ។ ដោយមិនមានការណែនាំពីអ្នកដឹកនាំរដ្ឋាភិបាល អ្នកមានវិជ្ជាជីវៈដែលមានបទពិសោធន៍ ឬ អ្នកគ្រប់គ្រងអាជីវកម្មនោះទេ ពួកគេអាចប្រឈមនឹងការក្លាយជាមនុស្សដែលមិនសំខាន់ ហើយអាចឈានទៅដល់មានអំពើហឹង្សា ឧក្រិដ្ឋកម្ម និង ឥរិយាបថដែលសង្គមមិនទទួលយកផ្សេងៗទៀត ។

## តំណាង និង សំលេង

ជាញឹកញាប់ យុវជននៅក្នុងប្រទេសកម្ពុជាមិនមានច្រកច្រើននោះទេដើម្បីបញ្ចេញទស្សនៈរបស់ពួកគេ អំពីគោលនយោបាយ និង កម្មវិធីដែលប៉ះពាល់ដល់ឱកាសរបស់ពួកគេសំរាប់ទទួលបានការងារដែលសមរម្យ និង ប្រកបដោយផលិតភាព ។ បន្ថែមលើសពីសមាគមយុវជន ក៏មានសក្តានុពលដើម្បីផ្តល់តួនាទីកាន់តែសំខាន់ថែមទៀតដល់យុវជនផងដែរ នៅក្នុងអង្គភាពនិយោជក និង សហជីព ។

*ទំនាក់ទំនងរវាងភាពគ្មានការងារធ្វើ និង សុខភាព*

យុវជនដែលគ្មានទំនាក់ទំនងជាមួយនឹងការអប់រំ និង ការងារ ប្រឈមមុខនឹងជំងឺកាមរោគ ការប្រើប្រាស់គ្រឿងញៀន និង មេរោគអេដស៍/ជំងឺអេដស៍ ។ កម្មវិធីតាមសាលារៀន និងកន្លែងធ្វើការ អាចយកមកប្រើប្រាស់ដើម្បីប្រាប់ទៅដល់យុវជនអំពីគ្រោះថ្នាក់និងវិធីបង្ការ ។

## អាទិភាពរបស់ផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ (NSDP)

ផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ ២០០៦-២០១០ ដាក់ចេញនូវវិធានការនានាដើម្បីអនុវត្តយុទ្ធសាស្រ្តចតុកោណ និង សំរេចអោយបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាសំរាប់ឆ្នាំ ២០១០ ។ ផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ លើកឡើងពីគោលនយោបាយដែលមានលក្ខណៈជាប្រព័ន្ធ "ដើម្បីបង្កើតការងារអោយបានច្រើនជាងមុន ជាពិសេសសំរាប់ប្រជាជនក្មេងៗដែលកំពុងចូលខ្លួនក្នុងទីផ្សារពលកម្ម និង សម្រាប់ពលរដ្ឋកម្ពុជាទាំងអស់តាមរយៈវិធានការទាំងឡាយ" (៤.៨១) ។ ចំនុចដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងយុវជននៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ ចង្អុលចំបញ្ហានៃភាពគ្មានការងារធ្វើ ការធ្វើចំណាកស្រុក ថ្នាំញៀន ការអប់រំ កីឡា សុខភាពបន្តពូជ និង ការបង្ការមេរោគអេដស៍/ជំងឺអេដស៍ ៖

- "ដូចនេះ បញ្ហាយុវជនគឺជាកង្វល់និងបញ្ហាប្រឈមមួយដ៏សំខាន់ ជាពិសេសនៅពេលណាដែលមានការកើតឡើងនៃភាពគ្មានការងារធ្វើ និង ការធ្វើបំលាស់ទីលំនៅរបស់យុវជន ហើយនៅពេលណាដែលមានការកើនឡើងនៃសញ្ញានៃឥរិយាបទប្រកបដោយហានិភ័យរបស់យុវជន ក្នុងនោះមាន ការប្រើប្រាស់គ្រឿងញៀនជាដើម" (២.៦៧) ។
- "ទិសដៅរយៈពេលវែង គឺដើម្បីធានាថាកុមារនិងយុវជនកម្ពុជាទាំងអស់មានឱកាសស្មើៗគ្នា ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព ដោយពុំគិតពីឋានៈក្នុងសង្គម តំបន់ភូមិសាស្រ្ត ជនជាតិ សាសនា ភាសា ភេទ ឬភាពពិការឡើយ" (៤.៨៥) ។
- ផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ គួរគាំទ្រដល់ "ការអភិវឌ្ឍន៍បន្ថែមទៀតក្នុងវិស័យយុវជននិងកីឡា ដោយបង្កើនការយកចិត្តទុកដាក់ចំពោះយុវជនក្នុងគ្រប់មុខជំនាញ" (៤.៨៨) ។




MPA
MPA



- ផែនការនេះអំពាវនាវអោយមានកិច្ចខិតខំប្រឹងប្រែងដើម្បី "កែលំអសេវា និង ព័ត៌មានពីសុខភាពបន្តពូជ រួមទាំងការពន្យារកំណើត និង ដោះស្រាយបញ្ហានិងសេវា សុខភាពផ្លូវភេទនិងសុខភាពបន្តពូជរបស់យុវជន" (៤.៩៥) ។

# វិធីសាស្ត្ររបស់អង្គការពលកម្មអន្តរជាតិ

ក្នុងរយៈពេលជាច្រើនឆ្នាំនេះ អង្គការពលកម្មអន្តរជាតិបានប្រើប្រាស់វិធីសាស្ត្រជាច្រើនដើម្បីដោះស្រាយបញ្ហាការងាររបស់យុវជន ។ ការងារ និង យុវជន គួរតែជាចំណុចស្នូលនៃគោលនយោបាយសំរាប់ការអភិវឌ្ឍន៍ និង កំណើនផ្នែកសង្គមនិងសេដ្ឋកិច្ច រួមជាមួយនឹងអន្តរាគមន៍ចំគោលដៅនានា ដើម្បីដោះស្រាយនូវគុណវិបត្តិជាក់លាក់ដែលយុវជនចូលមកកាន់ទីផ្សារការងារកំពុងប្រឈមមុខ ។

### ការងារសមរម្យក្នុងកំឡុងវដ្តនៃជីវិត




ប្រភពៈ Urmila Sakar: ការអភិវឌ្ឍន៍ខ្សែផលិតផលៈ ការងាររបស់យុវជន បទបង្ហាញរៀបចំសំរាប់កិច្ចប្រជុំរបស់នាយកប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក របស់អង្គការពលកម្មអន្តរជាតិ ទីក្រុងបាងកក ថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០០៧ ។ ដកស្រង់ចេញពី អង្គការពលកម្មអន្តរជាតិ *ធ្វើអោយការងារសមរម្យក្លាយជាគោលដៅនៅអាស៊ី* របាយការណ៍របស់អគ្គនាយក វគ្គទី ២ ទីក្រុងប៊ូសាន សាធារណៈរដ្ឋកូរ៉េ ខែ តុលា ឆ្នាំ ២០០៥ ការិយាល័យប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិករបស់អង្គការពលកម្មអន្តរជាតិ ទីក្រុងបាងកក ទំព័រទី ៥៧ ។

អង្គការពលកម្មអន្តរជាតិប្រើប្រាស់ទស្សនៈវដ្តនៃជីវិត ដែលសំលឹងមើលលើឱកាសការងារនៅគ្រប់ដំណាក់កាលនៃវ័យ ។ ការងាររបស់យុវជន មិនអាចកាត់ផ្តាច់ចេញពីពលកម្មកុមារ ការងាររបស់មនុស្សពេញវ័យ និង វ័យចាស់ បានឡើយ ។ នៅក្នុងដំណាក់កាលនៃវ័យនីមួយៗ អង្គការពលកម្មអន្តរជាតិ មានការព្រួយបារម្ភអំពីការងារសមរម្យ ដែលរួមមានគុណភាពការងារ និង ចំនួនការងារ ។

អង្គការពលកម្មអន្តរជាតិ ដើរតួនាទីជាលេខាធិការដ្ឋាន សំរាប់បណ្តាញការងារយុវជន (YEN) ដែលជាកិច្ចសហការជាដៃគូរវាង អង្គការសហប្រជាជាតិ អង្គការពលកម្មអន្តរជាតិ និង ធនាគារពិភពលោក ។ បណ្តាញការងារយុវជនបាននិងកំពុងធ្វើការងារ តាមរយៈបណ្តាញសកល ផែនការសកម្មភាព និង យុទ្ធសាស្ត្រអនុវត្តន៍ នៅកំរិតថ្នាក់ប្រទេស ដោយគាំទ្រលើ "៤-Es" ដើម្បី លើកកំពស់ភាពអាចរកការងារធ្វើបាន (employability) ធានាអោយមានសមភាព (equality) លើកកំពស់សហគ្រិនភាព (entrepreneurship) និង បង្កើតការងារ (employment) សំរាប់យុវជន ។

"សេចក្តីសំរេចពាក់ព័ន្ធនឹងការងាររបស់យុវជន" នៃសន្និសីទរបស់អង្គការពលកម្មអន្តរជាតិ កាលពីខែ មិថុនា ឆ្នាំ ២០០៥ ពិពណ៌នាអំពីអាទិភាពជាច្រើនសំរាប់ការអនុវត្តន៍ ។ ការងាររបស់យុវជន មានសារៈសំខាន់ដើម្បីសំរេចអោយបាននូវទស្សវត្សរ៍ការងារសមរម្យសំរាប់អាស៊ីរបស់អង្គការពលកម្មអន្តរជាតិ ដែលបានលើកឡើងនៅឯកិច្ចប្រជុំប្រចាំតំបន់អាស៊ីលើកទី ១៤ ក្នុងឆ្នាំ ២០០៦ ។

អង្គការពលកម្មអន្តរជាតិ បានធ្វើការងារនៅក្នុងផ្នែកជាច្រើនៈ លើកសំណូមពរជាគោលនយោបាយ និង កម្មវិធីដើម្បីសំរបសំរួលបំលាស់ប្តូររបស់យុវជន ជាពិសេសយុវជនមានផលលំបាក តាំងពីនៅសាលារៀនដល់ពេលធ្វើការងារ ។ ផ្តល់ជាជំនួយការបណ្តុះបណ្តាលជំនាញ និង ការណែនាំពីមុខរបរ ។ បង្កើតនូវវិធីសាស្ត្រដើម្បីផ្តល់ឱកាសការងារសំរាប់យុវជននៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងប្រទេស ។ ដោះស្រាយគុណភាពការងារ និង ល័ក្ខខ័ណ្ឌការងារ តាមរយៈជំហ៊ាននានាដើម្បីលើកកំពស់សុវត្ថិភាពនិងសុខភាពការងារ បង្ការមិនអោយមានទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដោះស្រាយបញ្ហាប្រឈមដែលទាក់ទងទៅនឹងមេរោគ អេដស៍/ជំងឺអេដស៍ និង កាត់បន្ថយអសមភាពយេនឌ័រ ។ បញ្ចូលការងាររបស់យុវជនទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ និងគាំទ្រដល់ស្ថាប័នត្រីភាគី ដើម្បីអោយចូលរួមនៅក្នុងការជជែកវែកញែកលើគោលនយោបាយ ។

ជាអកុសល ពលកម្មកុមារជាញឹកញាប់គឺជាករណីដែលកើតមានទន្ទឹមគ្នានឹងភាពគ្មានការងារធ្វើរបស់យុវជន ។ ខណៈពេលដែលកុមារនៅកន្លែងធ្វើការ ជាជាងក្នុងសាលារៀន

ដែលជាកន្លែងពួកគេគួរនៅ ការផ្គត់ផ្គង់កំលាំងការងាររបស់យុវជន ប្រែជាមិនត្រូវបានប្រើប្រាស់ ឬប្រើប្រាស់មិនទាន់អស់លទ្ធភាព ។ យុវជនជាច្រើន ដែលមានអាយុលើសពីកំរិតអាយុធ្វើការងារអប្បបរមា និង ក្រោម ១៨ ឆ្នាំ មិនមានបំលាស់ប្តូរដោយរលូនពីពេលនៅសាលារៀនដល់ពេលធ្វើការឡើយ ។ ដោយមិនបានទទួលគ្រប់គ្រាន់នូវការអប់រំ ការបណ្តុះបណ្តាល និង ការហ្វឹកហាត់ការងារដែលស៊ីគ្នាជាមួយនឹងតំរូវការទីផ្សារការងារនៅក្នុងប្រទេស យុវជនក្មេងៗទាំងនេះ ងាយរងគ្រោះទៅនឹងទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។ តាមពិតទៅ ពលកម្មកុមារ ធ្វើអោយបញ្ហាការងារយុវជនរឹតតែអាក្រក់ ។ ការឈប់រៀននៅវ័យក្មេង ធ្វើអោយកុមារមិនអាចត្រៀមខ្លួន ដើម្បីស្វែងរកការងារដែលមានផលិតភាពដើម្បីធ្វើនៅពេលក្រោយក្នុងជីវិត និង បង្កើនហានីភ័យនៃការធ្លាក់ចូលទៅក្នុងអន្ទាក់នៃភាពក្រីក្រ ដែលជាហេតុធ្វើអោយពួកគេមិនអាចផ្គត់ជាជីវភាពរស់នៅសំរាប់គ្រួសាររបស់ពួកគេ និង ការអប់រំសំរាប់កូនរបស់ពួកគេ ។

វិធានការនានាអាចត្រូវបានធ្វើឡើង ដើម្បីតំរង់ទិសនៃតំរូវការកំលាំងការងារពីកុមារឆ្ពោះទៅរកយុវជន ដោយធានាថាស្ត្រីក្មេងៗ និង បុរសក្មេងៗ ត្រូវបានការពារពីការកេងប្រវ័ញ្ចនៅក្នុងទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ [៧] ។ តាមរយៈគំរោងអនុតំបន់របស់អង្គការពលកម្មអន្តរជាតិ ដើម្បីបង្ការការជួញដូរស្ត្រីនិងកុមារ និង កម្មវិធីជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ការអន្តរាគមន៍នៅតាមសហគមន៍ជាច្រើនត្រូវបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ដើម្បីផ្តល់អោយកុមារនូវការអប់រំនិងការបណ្តុះបណ្តាល និង អោយគ្រួសារនូវជំរើសការងារ និង ការគាំទ្រដល់ជីវភាពរស់នៅរបស់ពួកគេ ។ ការលើកកំពស់ការយល់ដឹងអំពីការងារដែលមានគ្រោះថ្នាក់សំរាប់កុមារ និង ចំណាកស្រុកប្រកបដោយសុវត្ថិភាពសំរាប់យុវជន គឺជាធាតុសំខាន់ផងដែររបស់កម្មវិធីទាំងនេះ ។

គោលនយោបាយជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ កំពុងវិវត្តទៅមុខ តាមរយៈការបង្កើតជាផែនការសកម្មភាពជាតិដើម្បីបញ្ចប់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និង ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ។ គំនិតផ្តួចផ្តើមទាំងនេះ ត្រូវបានដឹកនាំដោយអ្នកពាក់ព័ន្ធត្រីភាគីរបស់អង្គការពលកម្មអន្តរជាតិ និង ដៃគូសង្គមស៊ីវិលនៅកំរិតជាតិ និង កំរិតសហគមន៍មូលដ្ឋាន ។ លើសពីនេះទៅទៀត អង្គការពលកម្មអន្តរជាតិបានអនុវត្តមូលដ្ឋានគ្រឹះនេះ តាមរយៈគំរោងនានាជាច្រើនសំរាប់ការងារសមរម្យនៅក្នុង សេដ្ឋកិច្ចក្រៅប្រព័ន្ធ ការផ្តល់អំណាចដល់ស្ត្រី ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច សកម្មភាពរកប្រាក់ចំណូល និង ការសិក្សាពីគ្នាទៅវិញទៅមកសំរាប់ជនពិការ ។

៧ សូមមើល អង្គការពលកម្មអន្តរជាតិ: *និន្នាការការងារ និង សង្គម នៅក្នុងអាស៊ាន ឆ្នាំ២០០៧: សមាហរណកម្ម បញ្ហាប្រឈម និង ឱកាស* ការិយាល័យប្រចាំតំបន់សំរាប់អាស៊ី និង ប៉ាស៊ីហ្វិក ទីក្រុងបាងកក ឆ្នាំ២០០៧ ។

គំរោងថ្មីមួយ ដែលត្រូវបានអនុវត្តដោយអង្គភាពនិយោជកនិងសហជីព និង ទទួលមូលនិធិពីប្រទេសណាវេ នឹងលើកកំពស់ការងាររបស់យុវជន និង កិច្ចសន្ទនាសង្គម ។

## ជំរើសគោលនយោបាយ

### *លើកកំពស់ភាពអាចរកការងារធ្វើបាន*

- ផ្តល់ជំនាញស្នូលដល់យុវជនគ្មានជំនាញ ដែលមានកំរិតអប់រំក្នុងប្រព័ន្ធទាប
- ជំរុញនិយោជកអោយចូលរួមក្នុងការកំណត់បទដ្ឋានជំនាញនិងតំរូវការបណ្តុះបណ្តាល
- ផ្សារភ្ជាប់ការបណ្តុះបណ្តាលនិងការងារ ដោយធ្វើតាមឧទាហរណ៍ល្អៗនៅក្នុងតំបន់
- បង្កើតប្រព័ន្ធបង្កើតថ្មី សំរាប់ការបណ្តុះបណ្តាលនៅកន្លែងធ្វើការ និង ការហ្វឹកហាត់ការងារសំរាប់យុវជន
- តស៊ូមតិអោយមានការអប់រំដែលមានគុណភាពល្អ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង ការរៀនសូត្រយូរអង្វែង

### *ការអភិវឌ្ឍន៍នៅក្នុងស្រុក*

- បង្កើតគំរោងដើម្បីលើកកំពស់ការបង្កើតការងារសមរម្យនៅក្នុងស្រុក នៅតាមកន្លែងបញ្ជូនកំលាំងការងារចំណាកស្រុក ដូចជាតាមខេត្តជាប់ព្រំដែន និងកន្លែងទទួលកំលាំងការងារចំណាកស្រុកនៅតាមតំបន់ទីក្រុង ដូចជាទីក្រុងភ្នំពេញ
- លើកកំពស់សេវាផ្សព្វផ្សាយកសិកម្ម តាមវិធីដែលនឹងផ្តល់ការងារ និង អត្ថប្រយោជន៍អោយដល់យុវជន
- លើកកំពស់ការយល់ដឹងនៅតាមមូលដ្ឋាន អំពីការងារគ្រោះថ្នាក់សំរាប់កុមារ និង ចំណាកស្រុកប្រកបដោយសុវត្ថិភាពសំរាប់យុវជន

### *ការងារដោយផ្ទាល់*

- បង្កើតក្រុមការងារមួយសំរាប់យុវជន ដោយផ្តោតលើជំនាញបំណិនជីវិត និងការអភិវឌ្ឍន៍សហគមន៍ និង ដោះស្រាយការព្រួយបារម្ភនានា ដូចជាបញ្ហាបរិស្ថានជាដើម

- អោយយុវជនចូលរួមនៅក្នុងការអភិវឌ្ឍន៍ និង ការថែទាំហេដ្ឋារចនាសម្ព័ន្ធ
- បង្កើតការងារថ្មីសំរាប់យុវជននៅក្នុងសេវាសាធារណៈ ដើម្បីលើកកំពស់សេវាសង្គមសំរាប់ការអប់រំ និង សុខភាព
- ដាក់អោយអនុវត្តនូវវិធានការជាក់លាក់នានា ដើម្បីផ្សព្វផ្សាយអោយដល់យុវជនមានផលលំបាក ដោយរួមទាំងយុវជនក្រីក្រដែលកំពុងធ្វើការងារជាដើម

## *សហគ្រិនភាពសំរាប់យុវជន*

- ធានាថាការរីកចំរើនបរិយាកាសអាជីវកម្ម ផ្តល់អត្ថប្រយោជន៍ទៅអោយយុវជន
- សាកល្បងប្រើប្រាស់សំភារៈរបស់អង្គការពលកម្មអន្តរជាតិស្តីពី "ដឹងអំពីអាជីវកម្ម" (KAB) នៅតាមសាលាមធ្យមសិក្សា និង ស្ថាប័នបណ្តុះបណ្តាល
- ពង្រឹងសេវាអភិវឌ្ឍន៍ផ្នែកអាជីវកម្មសំរាប់យុវជន
- បង្កើតកម្មវិធីពិនិត្យតាមដាន ដែលនៅក្នុងកម្មវិធីបែបនេះ ក្រុមហ៊ុនមួយផ្តល់ការគាំទ្រដល់អាជីវកម្មរបស់ យុវជន

## *កែលំអព័ត៌មាន*

- កសាងមូលដ្ឋានចំណេះដឹងអំពីការងាររបស់យុវជននៅក្នុងប្រទេសកម្ពុជា
- លើកទឹកចិត្តអោយការបោះពុម្ពផ្សាយនានាដែលចេញពីការសិក្សាថ្នាក់ជាតិ រួមបញ្ចូលនូវស្ថិតិសំរាប់យុវជន (១៥-២៤ ឆ្នាំ) មនុស្សជំទង់ (១៥-១៩ ឆ្នាំ) និង មនុស្សទើបពេញវ័យ (២០-២៤ ឆ្នាំ)
- ធ្វើការសិក្សាលើបំលាស់ប្តូរពីពេលនៅសាលារៀនដល់ពេលធ្វើការ (SWTS)
- វិភាគ និង ប្រើប្រាស់ទិន្នន័យដែលទទួលបានពីការសិក្សាលើនិយោជក និង យុវជនរបស់សហព័ន្ធនិយោជក និង សមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA)
- បង្កើតការភ្ជាប់ទៅកាន់ព័ត៌មានរបស់យុវជន នៅលើវ៉ិបសាយដែលបង្កើតឡើងដោយក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំបង្កើតជា "សៀវភៅណែនាំសំរាប់ដាក់ក្នុងហោប៉ៅ" ទាក់ទងនឹងការងាររបស់យុវជន ដោយមានព័ត៌មានអំពី ការស្វែងរកការងារ ការសរសេរប្រវត្តិរូប

បច្ចេកទេសសំភាសន៍ ស្ថាប័នបណ្តុះបណ្តាល អាជ្ញាប័ណ្ណដែលចាំបាច់ សិទ្ធិរបស់ស្រ្តី ខ្វិបសាយដែលមានប្រយោជន៍ និង ព័ត៌មានដទៃទៀត

- បង្កើតពិព័រណ៍ការងារសំរាប់យុវជន

## *ការចូលរួម និង សំលេងកាន់តែខ្លាំងជាងមុន*

- ភ្ជាប់គំនិតផ្តួចផ្តើមនានាជាមួយនឹងអង្គការដែលមានស្រាប់ ដូចជា CAMPRONET និង សមាគមយុវជនខ្មែរ
- គាំទ្រដល់គំរោងរបស់ អង្គការពលកម្មអន្តរជាតិ-ប្រទេសណរវ៉េ អំពីកិច្ចសន្ទនាសង្គម តាមរយៈ CAMFEBA និង សហជីព
- ពង្រឹងសមត្ថភាពអោយយុវជនចូលរួមនៅក្នុងការពិភាក្សាគោលនយោបាយអំពីការងារ
- កសាងទំនាក់ទំនងជាមួយនឹងបណ្តាញការងារយុវជន (YEN)
- រៀបចំអោយមានជាកិច្ចពិគ្រោះយោបល់រវាងយុវជននិងយុវជន អំពីបំណងប្រាថ្នា និង ឱកាសការងារ
- រៀបចំអោយមានសន្និសីទថ្នាក់ជាតិអំពីការងាររបស់យុវជន សំរាប់ការលើកកំពស់ការយល់ដឹង និង ការតស៊ូមតិផ្នែកគោលនយោបាយ

ការិយាល័យអនុតំបន់នៃអង្គការពលកម្មអន្តរជាតិសំរាប់អាស៊ីបូព៌ា
ទូរស័ព្ទ: +៦៦ ២ ២៨៨ ១៧១៧
ទូរសារ: +៦៦ ២ ២៨៨ ៣០៥៨
អ៊ីម៉េល: SRO-BKK@ilo.org

ការិយាល័យ Joint Project Office នៃអង្គការពលកម្មអន្តរជាតិនៅប្រទេសកម្ពុជា
ទូរស័ព្ទ: +៨៥៥ ២៣ ២២០ ៨១៧
ទូរសារ: +៨៥៥ ២៣ ២២១ ៥៣៦

ISBN: 978-92-2-820112-3